**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ បព ៦២/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុប លើកទី២៥

តបតាមការអញ្ជើញរបស់**ឯកឧត្តម ដាតុ អ៊ីរ៉ាវ៉ាន់ ពើហ៊ីន យូសូហ្វ** រដ្ឋមន្ត្រីការបរទេសទី២ នៃព្រុយណេដារូស្សាឡាម ក្នុងនាមជាប្រទេសសម្របសម្រួលនៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-សហភាពអឺរ៉ុប **ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុប លើកទី២៥ នៅថ្ងៃទី២៧-២៨ ខែមេសា ឆ្នាំ២០២៦ នៅរាជធានីបានដាសេរីបេហ្គាវ៉ាន់។

កិច្ចប្រជុំបានអះអាងជាថ្មីនូវភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-សហភាពអឺរ៉ុបដ៏រឹងមាំ និងពហុវិស័យដែលឈរលើមូលដ្ឋាននៃតម្លៃ និងប្រយោជន៍រួម ហើយដែលត្រូវបានកសាង និងពង្រឹងឡើងក្នុងរយៈពេលជាង ៤ទសវត្សរ៍កន្លងមក។ អាស៊ាន និងសហភាពអឺរ៉ុប បានគូសបញ្ជាក់អំពីវិសាលភាពនៃកិច្ចសហប្រតិបត្តិការក្រោមសសរស្តម្ភទាំងបីនៃសហគមន៍អាស៊ាន។ ក្នុងស្មារតីនេះ កិច្ចប្រជុំបានអនុម័តសេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុប លើកទី២៥ សំដៅពង្រឹងភាពជាដៃគូអាស៊ាន-សហភាពអឺរ៉ុប និងទន្ទឹងរង់ចាំការប្រារព្ធខួបលើកទី៥០ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-សហភាពអឺរ៉ុប នៅឆ្នាំក្រោយ។

នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ជាថ្មីនូវការគាំទ្ររបស់កម្ពុជាចំពោះសំណើរបស់សហភាពអឺរ៉ុប ដែលស្នើដំឡើងកម្រិតទំនាក់ទំនងភាពជាដៃគូអាស៊ាន-សហភាពអឺរ៉ុបទៅជាភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងសំណើរៀបចំកិច្ចប្រជុំកំពូលអាស៊ាន-សហភាពអឺរ៉ុបជាទៀងទាត់ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាព ក្នុងតំបន់ និងក្រៅតំបន់។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់អំពីសារៈសំខាន់នៃលទ្ធភាពបង្កើតកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-សហភាពអឺរ៉ុប ដែលជាកិច្ចព្រមព្រៀងកម្រិតតំបន់និងតំបន់ និងទន្ទឹងរង់ចាំការចូលជាធរមានដ៏ឆាប់នៃកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពីការដឹកជញ្ជូនផ្លូវអាកាសអាស៊ាន-សហភាពអឺរ៉ុប ដែលជាជំហានជាក់ស្តែងឆ្ពោះទៅរកការពង្រឹងការតភ្ជាប់អន្តរតំបន់ និងទំនាក់ទំនងរវាងប្រជាជននិងប្រជាជនឱ្យកាន់តែជិតស្និទ្ធ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានសម្តែងការអរគុណយ៉ាងខ្លាំងចំពោះការបន្តគាំទ្ររបស់សហភាពអឺរ៉ុបសម្រាប់កិច្ចសហប្រតិបត្តិការតំបន់។ ភាពនាំមុខរបស់សហភាពអឺរ៉ុបក្នុងវិស័យថាមពលបៃតង បទពិសោធ ក្នុងការធ្វើសមាហរណកម្មទីផ្សារអគ្គិសនី និងតួនាទីជាប្រភពវិនិយោគចម្បង គឺមានតម្លៃដ៏សំខាន់ចំពោះអាស៊ាន

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

ជាពិសេសក្នុងការជំរុញបណ្តាញអគ្គិសនីអាស៊ាន ដើម្បីគាំទ្រដល់សមាហរណកម្មថាមពលកកើតឡើងវិញ ការកាត់បន្ថយថ្លៃដើម ការបង្កើនទំនុកចិត្ត និងការពង្រឹងសមាហរណកម្មតំបន់។

នៅក្នុងទិដ្ឋភាពពិភពលោកដែលកាន់តែស្មុគស្មាញ ហើយត្រូវបានកត់សម្គាល់ដោយការកើនឡើងនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ និងការកើតឡើងវិញនៃជម្លោះប្រដាប់អាវុធនៅក្នុងផ្នែកជាច្រើននៃពិភពលោក **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការប្រកាន់ខ្ជាប់នូវការគោរពច្បាប់អន្តរជាតិ និងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ជាពិសេសការគោរពអធិបតេយ្យ និងបូរណភាពទឹកដី ការចៀសវាងនូវការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង និងការដោះស្រាយជម្លោះដោយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ។ គោលការណ៍ដូចគ្នានេះគឺជាមូលដ្ឋាននៃជំហរ និងការគោរពរបស់កម្ពុជាពាក់ព័ន្ធនឹងស្ថានភាពនៅតាមបណ្តោយព្រំដែនជាមួយប្រទេសថៃ។ ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអរគុណដល់ប្រទេសសមាជិកអាស៊ាន និងសហភាពអឺរ៉ុប ចំពោះការគាំទ្រដល់បទឈប់បាញ់រវាងកម្ពុជា និងថៃ ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងបន្តឆ្ពោះទៅរកដំណោះស្រាយជម្លោះដោយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ៕

ថ្ងៃអង្គារ ១២កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៦